# ធម្មនុញ្ញវិទ្យុសម្លេងសហរដ្ឋអាមេរិក

*ដើម្បីការពារ នូវ បូរណភាព នៃការផ្សាយ របស់វិទ្យុសម្លេងសហរដ្ឋអាមេរិក និង ដើម្បីបញ្ជាក់អត្ថន័យ នៃ បេសកម្ម របស់អង្គការផ្សាយនេះ ទើប ធម្មនុញ្ញ នៃ* VOA *សម្លេងសហរដ្ឋអាមេរិក បានត្រូវចុះហត្ថលេខា ដោយលោកប្រធានាធិបតី* Gerald Ford *ឲ្យចូលជាធរមាន ក្នុងថ្ងៃទី ១២ កក្កដា ឆ្នាំ ១៩៧៦ ។ ផលប្រយោជន៍ សម្រាប់រយៈកាលយូរ នៃ សហរដ្ឋអាមេរិក ត្រូវបំរើតាមរយៈ ការទាក់ទងគ្នាផ្ទាល់ដោយវិទ្យុ ជាមួយប្រជារាស្ត្រ ទាំងឡាយ នៃពិភពលោក ។ ដើម្បីឲ្យមានប្រសិទ្ធិភាព* VOA *សម្លេងសហរដ្ឋអាមេរិក ត្រូវតែទទួលបាននូវ ការយកចិត្តទុកដាក់ និង សេចក្ដីគោរព ពីសំណាក់ក្រុមអ្នកស្ដាប់ៗ ដោយហេតុនេះទើប គោលការណ៍ទាំងឡាយ ដូចតទៅនេះ និងមានអំណាច ពីលើការផ្សាយទាំងឡាយ របស់* VOA *សម្លេងសហរដ្ឋអាមេរិក ៖*

១- VOA *សម្លេងសហរដ្ឋអាមេរិក និងបំពេញតួនាទី ជាប្រភពនៃពត៌មាន ដែលគួរធ្វើឲ្យទុកចិត្ត អាចយកជាការបាន ដោយគ្មានការផ្លាស់ប្ដូរៗ ពត៌មានរបស់* VOA *សម្លេងសហរដ្ឋអាមេរិក និងត្រូវតែ ជាពត៌មាន ពិត មិនលំអៀង និងមានវិសាលភាពៗ*

២- VOA *សម្លេងសហរដ្ឋអាមេរិក និងតំណាងឲ្យប្រទេសអាមេរិក មិនមែនតំណាងឲ្យតែ ផ្នែកណាមួយ នៃសង្គមអាមេរិកាំង តែប៉ុណ្ណោះទេ និងដោយហេតុនេះហើយ ទើប* VOA *សម្លេងសហរដ្ឋអាមេរិក និងស្នើជូន នូវការសំដែង ដែលមានតុល្យភាព និងវិសាលភាព នូវគំនិត និងស្ថាប័នទាំងឡាយ ដែលមានសារៈសំខាន់ របស់អាមេរិកាំងៗ*

៣- VOA *សម្លេងសហរដ្ឋអាមេរិក និងបង្ហាញឲ្យឃើញ នូវមាគ៌ា នយោបាយ នៃសហរដ្ឋអាមេរិក ដោយច្បាស់លាស់ និង ដោយមានប្រសិទ្ធភាព ហើយក៏និងបង្ហាញឲ្យឃើញ នូវការពិភាក្សា និងមតិ ដែលមានការទទួលខុសត្រូវ ទៅលើមាគានយោបាយ ទាំងឡាយនេះ ផងដែរៗ*